ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សកា
MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

ភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០០១

លេខ : ៧៨៤ សកបយ.

# ប្រកាស
## ស្តីពី
## ប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សម្រេច

**ប្រការ១.-** សហគ្រាស គ្រឹះស្ថានទាំងអស់ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានប្រើកម្មករនិយោជិតចាប់ពីប្រាំបីនាក់ឡើងទៅ ត្រូវបង្កើតអោយមានប្រតិភូបុគ្គលិក។

ប្រតិភូពេញសិទ្ធិ ( ឬប្រតិភូបុគ្គលិកពេញសិទ្ធិ) ម្នាក់ត្រូវមានប្រតិភូជំនួយម្នាក់។

ប្រភេទសហគ្រាស គ្រឹះស្ថាន ដែលត្រូវអោយមានប្រតិភូបុគ្គលិកជាដាច់ខាតគឺសហគ្រាស គ្រឹះស្ថានឧស្សាហកម្ម ពាណិជ្ជកម្ម រ៉ែ សំណង់ សេវា ធនាគារ កសិកម្ម កំពង់ផែ សណ្ឋាគារ ភោជនីយដ្ឋាន សាលាបង្រៀន និងផលិតកម្មផ្សេងៗទៀត។ ប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយត្រូវបោះឆ្នោតជ្រើសរើសដោយ

កម្មករនិយោជិតសំរាប់អាណត្តិពីរឆ្នាំ ។

**ប្រការ២.-** បែបបទ និងរបៀបបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយត្រូវអនុវត្តដូចតទៅ :-

-សហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស គ្រឹះស្ថាន ជាអ្នកជ្រើសតាំងបេក្ខជនឈរឈ្មោះទៅតាមចំនួនអាសនៈ នៃប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ។ និយោជកត្រូវពិភាក្សាជាមួយសហជីពទាំងនោះដើម្បីកំណត់បែបបទ កាលបរិច្ឆេទនៃការបោះឆ្នោត និងចំនួនអាសនៈដែលត្រូវបែងចែកទៅអោយគណៈអ្នកបោះឆ្នោត ។

-នៅពេលដែលមិនទាន់មានសហជីពនៅក្នុងសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតមានសិទ្ធិពេញលេញដោយស្ម័គ្រចិត្តចុះឈ្មោះក្នុងបញ្ជីបេក្ខជន ដើម្បីអោយគេបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិនិងប្រតិភូជំនួយ ។ និយោជកត្រូវអញ្ជើញតំណាងកម្មករនិយោជិតដើម្បីពិភាក្សាគ្នាអំពីបែបបទចាត់តាំង កាលបរិច្ឆេទនៃការបោះឆ្នោត និងចំនួនអាសនៈដែលត្រូវបែងចែកទៅអោយគណៈអ្នកបោះឆ្នោត ។

-ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិជំនួយត្រូវធ្វើតាមរបៀបតែមួយ ប៉ុន្តែត្រូវធ្វើដាច់ដោយឡែកពីគ្នា។ ការបោះឆ្នោតត្រូវធ្វើដោយសំងាត់ ។ ការបោះឆ្នោតត្រូវធ្វើក្នុងម៉ោងធ្វើការ ។

- សហគ្រាស គ្រឹះស្ថានណាមានកម្មករនិយោជិតចាប់ពី ៥១ នាក់ ( ហាសិបមួយនាក់ ) ឡើងទៅការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយត្រូវបែងចែកជាពីរគណៈដាច់ដោយឡែក ។ គណៈអ្នកបោះឆ្នោតទី ១ គឺសំរាប់ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយដែលតំណាងអោយកម្មករនិយោជិតធម្មតា ។ គណៈអ្នកបោះឆ្នោតទី ២ គឺសំរាប់ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយដែលតំណាងអោយអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកមានសញ្ញាប័ត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើង និងអ្នកជំនាញជាន់ខ្ពស់ ។ ប៉ុន្តែបើចំនួនសរុប នៃអ្នកត្រូវបោះឆ្នោតក្នុងគណៈអ្នកបោះឆ្នោតទី ២ មានតិចជាងប្រាំបីនាក់នោះ ការបោះឆ្នោតអាចប្រព្រឹត្តទៅតែមួយគណៈរួមគ្នាតែម្តង ។

-និយោជកត្រូវបិទផ្សាយបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ព្រមទាំងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះជូនដល់កម្មករនិយោជិតបានជ្រាប យ៉ាងតិចក្នុងរយៈពេលបីថ្ងៃមុនថ្ងៃបោះឆ្នោត ។

-អ្នកបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការជ្រើសរើសបេក្ខជនដែលខ្លួនពេញចិត្ត ប៉ុន្តែត្រូវគោរពបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជាដាច់ខាត ។

-ក្រោយពេលប្រកាសផ្សាយបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ព្រមទាំងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះរួច មុននិងចែកសន្លឹកឆ្នោតដល់កម្មករនិយោជិតធ្វើការបោះឆ្នោត អ្នកទទួលខុសត្រូវរៀបចំការបោះឆ្នោតត្រូវអនុញ្ញាតអោយកម្មករនិយោជិតសម្រាករយៈពេលពីរម៉ោងដើម្បីធ្វើការត្រិះរិះពិចារណាដោយសេរីទៅលើបេក្ខជនដែលខ្លួនពេញចិត្ត ។

-ចំពោះសហគ្រាស គ្រឹះស្ថានដែលមានសាខាច្រើនហើយសាខានីមួយៗមានកម្មករនិយោជិតចាប់ពី

ប្រាំបីនាក់ឡើងទៅត្រូវធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយតាមសាខានីមួយៗ ដាច់ដោយឡែកពីគ្នា ។

-ក្នុងករណីបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិថ្មី ការបោះឆ្នោតត្រូវប្រព្រឹត្តទៅក្នុងរយៈពេលដប់ប្រាំថ្ងៃមុនពេលបញ្ចប់អាណត្តិប្រតិភូបុគ្គលិក ។

-និយោជកត្រូវទទួលខុសត្រូវការរៀបចំបោះឆ្នោតនេះ ទាំងផ្នែកសំភារៈ ហិរញ្ញវត្ថុ និងស្មារតី ។

**ប្រការ៣.-** ប្រតិភូបុគ្គលិកក្នុងនាមជាតំណាងស្របច្បាប់របស់កម្មករនិយោជិត ត្រូវបំពេញភារៈកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវ និងស្មោះត្រង់ ។

ប្រតិភូបុគ្គលិកមានបេសកកម្មជាអាទិ៍ :

-នាំពាក្យប្រាប់និយោជកអំពីសេចក្តីតវ៉ារបស់កម្មករនិយោជិតម្នាក់ៗ ឬច្រើននាក់រួមគ្នា ដែលមិនសុខចិត្តអំពីការអនុវត្តន៍ប្រាក់ឈ្នួល ការអនុវត្តន៍នីតិក្រម និងបទបញ្ជាទូទៅនៃការងារ ហើយនឹងអនុសញ្ញារួមសំរាប់អនុវត្តនៅក្នុងសហគ្រាស គ្រឹះស្ថាន

-ជំរាបជូនអធិការការងារនូវបណ្តឹងតវ៉ាមិនសុខចិត្ត និងការរិះគន់ផ្សេងៗពាក់ព័ន្ធដល់ការអនុវត្តន៍បទប្បញ្ញត្តិច្បាប់ និងបទបញ្ជាការងារដែលអធិការការងារមានភារកិច្ចត្រួតពិនិត្យ

-មើលខុសត្រូវលើការអនុវត្តន៍បទប្បញ្ញត្តិខាងអនាម័យ និងខាងសន្តិសុខការងារ

-លើកសំណូមពរនូវវិធានការដែលមានប្រយោជន៍ សំរាប់រួមចំណែកការពារសុខភាព កែលំអសន្តិ-សុខ និងល័ក្ខខ័ណ្ឌការងាររបស់កម្មករនិយោជិតដែលធ្វើការក្នុងសហគ្រាស គ្រឹះស្ថាន ពិសេសក្នុងករណីមានគ្រោះថ្នាក់ការងារ ឬមានជំងឺវិជ្ជាជីវៈ ។

-ជូនយោបល់ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង ឬលើគម្រោងនៃការកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថានខ្លួន ។

-ជូនយោបល់ជាលាយលក្ខណ៍អក្សរលើវិធានការដែលគេបានគ្រោងឡើងសំរាប់ការបញ្ឈប់កម្មករនិយោជិតដោយសារកាត់បន្ថយសកម្មភាព ឬការរៀបចំផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថានខ្លួន ។

**ប្រការ៤.-** និយោជកត្រូវធ្វើកំណត់ហេតុនៅរាល់ពេលធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ។ ចំពោះសហគ្រាស គ្រឹះស្ថានទាំងអស់នៅរាជធានីភ្នំពេញ ត្រូវផ្ញើកំណត់ហេតុនេះមួយច្បាប់ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដែលស្ថិតនៅអាគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក ( ផ្លូវលេខ១៨៤ ) សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញរាជធានីភ្នំពេញ។ ចំពោះសហគ្រាស គ្រឹះស្ថាននៅតាមខេត្ត - ក្រុង ត្រូវផ្ញើកំណត់ហេតុនេះមួយច្បាប់ទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត -ក្រុង នៃមូលដ្ឋានខ្លួន ។ កំណត់ហេតុនេះ ត្រូវផ្ញើយ៉ាងយូរបំផុតក្នុងរយៈពេលប្រាំបីថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។

<u>ប្រការ៥</u>.- និយោជកត្រូវផ្តល់អោយប្រតិភូបុគ្គលិក នូវទីកន្លែងធ្វើការ ទីកន្លែងប្រជុំ សំភារៈធ្វើការ នឹងទីកន្លែងសំរាប់ការបិទផ្សាយផ្សេងៗ ដ៏សមស្រប ។

<u>ប្រការ៦</u>.- និយោជកត្រូវអនុញ្ញាតអោយប្រតិភូបុគ្គលិកម្នាក់ៗ នូវពេលវេលាពីរម៉ោងក្នុងមួយសប្តាហ៍ សំរាប់បំពេញការងាររបស់ខ្លួន ដោយរក្សាទុកប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំផ្សេងៗ ដែលធ្លាប់បានទទួលនៅដដែល ។ ក្នុងករណីពិសេស និងដោយមានការឯកភាពពីនិយោជកផង ប្រតិភូបុគ្គលិកម្នាក់ៗ អាចបំពេញការងាររបស់ខ្លួនលើសពីថិរវេលាកំណត់នេះ ។

<u>ប្រការ៧</u>.- កម្មករនិយោជិតអាចបណ្តេញប្រតិភូបុគ្គលិកពីតំណែងមុនពេលចប់អាណត្តិបាន ក្នុងករណីដែលប្រតិភូ-បុគ្គលិកនោះមិនបានបំពេញភារកិច្ចរបស់ខ្លួន ។ ការសំរេចស្តីពីការបណ្តេញចេញនេះ ត្រូវធ្វើឡើងតាមរបៀប និងបែបបទបោះឆ្នោត ដូចគ្នានឹងពេលជ្រើសរើសជននោះដែរ ។ កម្មករនិយោជិតត្រូវជូនដំណឹងជាផ្លូវការទៅអធិការការងារក្នុងរយៈពេលបីថ្ងៃយ៉ាងយូរក្រោយពីពេលសំរេចបណ្តេញប្រតិភូបុគ្គលិកចេញពីតំណែង ។ ពេលប្រតិភូពេញសិទ្ធិត្រូវបណ្តេញចេញពីតំណែង ប្រតិភូជំនួយនឹងទទួលការងារនេះជំនួសរហូតដល់ពេលមានការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកសំរាប់អាណត្តិថ្មី ។

<u>ប្រការ៨</u>.- ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរបំផុត០៦ខែ ក្រោយពេលបើកសហគ្រាស គ្រឹះស្ថាន ។

<u>ប្រការ៩</u>.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៧០ប្រក.អក-ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ លេខ ១៤៦ សកអ-ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ និងលេខ ៦៥៩ សកអ-ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៦</u>.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>**ចម្លងជូន**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក
-សហព័ន្ធសហជីព

"ដើម្បីជ្រាប"